ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្ដីប្រកាសព័ត៌មានរួម
# ស្ដីពី
# ពិធីប្រគល់ទទួល និងប្រកាសឱ្យប្រើប្រាស់បទដ្ឋានបច្ចេកទេសសំណង់ផ្លូវ និងស្ពាន ក្នុងជំហានទី១ និងប្រកាសជំនួយបច្ចេកទេស ជំហានទី២

ក្រសួងសាធារណការ និងដឹកជញ្ជូន នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី តាមរយៈកម្មវិធីភាពជាដៃគូសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ (P4I) បានសហការរៀបចំ "ពិធីប្រគល់ទទួល និងប្រកាសឱ្យប្រើប្រាស់បទដ្ឋានបច្ចេកទេសសំណង់ផ្លូវ និងស្ពាន ជំហានទី១ និងប្រកាសជំនួយបច្ចេកទេស ជំហានទី២" ដែលបានប្រព្រឹត្តទៅនារសៀលថ្ងៃពុធ ទី៥ ខែមីនា ឆ្នាំ២០២៥ ក្រោមគណៈអធិបតីភាព **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង **ឯកឧត្តម ដេរិក យីប** (Derek YIP) ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា។

ពិធីនេះគឺជាការប្រកាសឱ្យប្រើប្រាស់ជាផ្លូវការនូវបទដ្ឋានបច្ចេកទេសថ្មី ដែលកើតចេញពីចំណងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-អូស្ត្រាលី និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការរៀបចំកែសម្រួល និងធ្វើបច្ចុប្បន្នភាពបទដ្ឋានបច្ចេកទេសតាំងពីឆ្នាំ២០០០ ដើម្បីឆ្លើយតបនឹងតម្រូវការនាពេលបច្ចុប្បន្ន ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវ និងស្ពានក្នុងព្រះរាជាណាចក្រកម្ពុជា។

ពិធីនេះក៏បានបង្ហាញពីទំនាក់ទំនងជិតស្និទ្ធ និងស៊ីជម្រៅរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសអូស្ត្រាលី ដែលឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តរបស់កម្ពុជាក្នុងការធ្វើពិពិធកម្មដៃគូអន្តរជាតិ និងការពង្រឹងស្វ័យភាពជាយុទ្ធសាស្ត្រមួយកម្រិតទៀត។

នាឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី ប៉េង ពោធិ៍នា** បានមានប្រសាសន៍ថា "បទដ្ឋានបច្ចេកទេសដែលទទួលបានការគាំទ្រពីមិត្តអូស្ត្រាលី គឺជាទំព័រថ្មីមួយបន្ថែមទៀត សម្រាប់បន្តរួមចំណែកលើកកម្ពស់ និងអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវ និងស្ពានរបស់កម្ពុជា។ បទដ្ឋានបច្ចេកទេសផ្លូវ និងស្ពានដែលបានធ្វើបច្ចុប្បន្នភាពទាំងនេះ រួមជាមួយនឹងកម្មវិធីពង្រឹងសមត្ថភាពនឹងជួយឱ្យយើងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្លូវ និងស្ពានប្រកបដោយសុវត្ថិភាព ធន់ និងធានានិរន្តរភាពក្នុងការប្រើប្រាស់ឱ្យកាន់តែប្រសើរ ដើម្បីបំពេញតម្រូវការរបស់អ្នកប្រើប្រាស់ និងជួយជំរុញពិពិធកម្មវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវ និងស្ពាននៃព្រះរាជាណាចក្រកម្ពុជា ប្រកបដោយសោភ័ណភាព និងគុណភាព"។

**ឯកឧត្តមឯកអគ្គរដ្ឋទូត ដេរិក យីប** បានរម្លឹកឡើងវិញនូវការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីក្នុងការគាំទ្រដល់គោលដៅអភិវឌ្ឍន៍ជាតិរបស់កម្ពុជា និងបានបញ្ជាក់បន្ថែមថា "ភាពជាដៃគូរវាងកម្ពុជា-អូស្ត្រាលី បានបង្ហាញពីទំនាក់ទំនងដ៏រឹងមាំរវាងប្រជាជាតិទាំងពីរ។ រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលីរីករាយនឹងជួយគាំទ្រដល់ប្រទេសកម្ពុជាក្នុងការកសាង និងអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឱ្យបានសមស្រប ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ច សង្គមប្រកបដោយបរិយាបន្ន និងភាពធន់ទៅនឹងការបម្រែបម្រួលអាកាសធាតុ"។

ក្រៅពីពិធីប្រគល់-ទទួលឯកសារបទដ្ឋានបច្ចេកទេសនេះ ក៏មានការប្រកាសពីជំនួយបច្ចេកទេសជំហានទី២ ផ្តោតលើការកសាងសមត្ថភាពរបស់វិស្វករជំនាញ និងមន្ត្រីបច្ចេកទេសកម្ពុជា ក្នុងការពង្រឹងសមត្ថភាពអនុវត្តបទដ្ឋានបច្ចេកទេសថ្មីៗឱ្យមានប្រសិទ្ធភាពជាអតិបរមា តាមរយៈការរៀបចំសិក្ខាសាលាកម្មវិធីបណ្តុះបណ្តាល និងការចែករំលែកចំណេះដឹង ដែលនឹងប្រែក្លាយជាកម្លាំងចលករជួយជំរុញដ៏មានសក្តានុពលក្នុងការប្រើប្រាស់បទដ្ឋានបច្ចេកទេសទាំងនេះឱ្យកាន់តែទូលំទូលាយ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៥

- កម្មវិធី P4I គឺជាគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលនៃប្រទេសអូស្ត្រាលី ដែលគាំទ្រការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រកបដោយនិរន្តរភាព និងបរិយាបន្ននៅក្នុងតំបន់អាស៊ីអាគ្នេយ៍
- **About AustRoads**

  Austroads គឺជាសមាគមនៃភ្នាក់ងារចរាចរណ៍ និងដឹកជញ្ជូនផ្លូវគោកនៃប្រទេសអូស្ត្រាលី
- សម្រាប់ព័ត៌មានបន្ថែម:

  ស្ថានទូតអូស្ត្រាលី: Media.Cambodia@dfat.gov.au